# ព្រឹត្តិបត្រអង្គការស្ត្រីខ្មែរកម្ពុជាក្រោម

**Khmer Kampuchea Krom Women Organization Bulletin**

ចេញផ្សាយប្រចាំអឌ្ឍមាស ឆ្នាំទី២ លេខ១៣ ពីថ្ងៃទី០១-១៥ ខែកុម្ភៈ ឆ្នាំ២០០៨


## ពត៌មានពេញចំណាប់

បន្ទាប់ពីព្រះសង្ឃសាលាបាលីនៅខេត្តឃ្លាំងនៃដែនដីកម្ពុជាក្រោមបានធ្វើបាតុកម្មអហិង្សាក្នុងរយៈពេលពីថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០០៧ ក្នុងគោលបំណងទាមទារសិទ្ធិបញ្ចេញមតិជំនឿសាសនា និងការគោរពប្រតិបត្តិប្រពៃណី ទំនៀមទំលាប់ វប្បធម៌របស់ខ្មែរនៅដែនដីកម្ពុជាក្រោម ដែលជាទឹកដីម្ចាស់ការបស់ខ្លួនរួចមក ត្រូវបានអាជ្ញាធរយួនបង្ក្រាបមកលើសមណៈនិស្សិតរបស់យើងយ៉ាងឃោរឃៅព្រៃផ្សៃជាទីបំផុត ។ ក្នុងនោះក៏មានចាប់ព្រះសង្ឃយកទៅធ្វើទារុណកម្មរហូតដល់ផ្សឹកដាក់ពន្ធនាគារ

ទិដ្ឋភាពសមណៈនិស្សិតសាលាបាលីនៅខេត្តឃ្លាំង កម្ពុជាក្រោមបានធ្វើបាតុកម្មអហិង្សា ដើម្បីទាមទារសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងការជំនឿសាសនា កាលពីថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០០៧កន្លងមក



**Khmer Kampuchea Krom Buddish Monks protest in front of Pali School, in Klang Province, Kampuchea Krom Land (south Vietnam) on 08-Feb-2007**


អាសយដ្ឋាន: ផ្ទះលេខ១៩ ផ្លូវ២៩៤ ក្រុម៦៨ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ

ទូរស័ព្ទ: ០១១ ៩១ ២៣ ២៨ / ០៩៩ ៩៧ ៨៨ ៨៣

E-mail: kkkwo@yahoo.com


ចែកជូនដោយឥតគិតថ្លៃ



ចំនួន០៥អង្គទៀតផង រាល់ការកាត់ទោសរបស់អាជ្ញាធរយួនចំពោះសមណៈនិស្សិតខ្មែរកម្ពុជាក្រោមទាំង០៥ព្រះអង្គនោះ ក្នុងមួយអង្គៗចាប់ពី០២ឆ្នាំទៅ០៤ឆ្នាំ ប៉ុន្តែឥឡូវនេះព្រះសង្ឃទាំង០៥ព្រះអង្គនោះជាប់ពន្ធនាគារបានត្រឹមតែជាង១ឆ្នាំ ក៏ត្រូវបានអាជ្ញាធរយួនដោះលែងមកវិញ តើការដោះលែងរបស់អាជ្ញាធរយួនអំពីបញ្ហាសមណៈនិស្សិតខ្មែរកម្ពុជាក្រោម ដោយសារយួនអាណិតខ្មែរ ឬមួយត្រូវតំណាងពីបរទេស តាមទស្សនៈរបស់អ្នកវិភាគនយោបាយឯករាជ្យជាច្រើនបានយល់ឃើញថាយួនមិនមែនអាណិតខ្មែរ ហើយក៏មិនមែនស្រឡាញ់ខ្មែរដូចខ្មែរគ្នាឯងទេ ការដែលយួនដោះលែងព្រះសង្ឃជាសមណៈនិស្សិតខ្មែរកម្ពុជាក្រោមទាំង០៥ព្រះអង្គនៅខេត្តឃ្លាំង ក្នុងទឹកដីកម្ពុជាក្រោមនោះ គឺដោយសារអង្គការ សមាគមខ្មែរកម្ពុជាក្រោមទាំងក្នុង និងក្រៅប្រទេសបានខិតខំប្រឹងប្រែងទាំងអស់គ្នា ស្រែកបន្លឺឡើងរហូតដល់អង្គការជាតិ និងអង្គការអន្តរជាតិពាសពេញពិភពលោក ក៏រួមគំនិតគ្នាថ្កោលទោសយ៉ាងខ្លាំងក្លាជាទីបំផុត ចំពោះអាជ្ញាធរយួនដែលបានរំលោភសិទ្ធិ រំលោភសិទ្ធិមនុស្ស និងការបំបិទសិទ្ធិសេរីភាពជំនឿសាសនា ប្រពៃណី ទំនៀមទំលាប់វប្បធម៌ ព្រមទាំងពុំមានការគោរពនូវសិទ្ធិនៃម្ចាស់ដើមរបស់ជនជាតិ ពិសេសទៅទៀតនោះគឺ [illegible] ដែលបានខិតខំប្រឹងប្រែងដើរតួយ៉ាងសកម្មក្នុងបញ្ហាខ្មែរកម្ពុជាក្រោមនេះតែម្តង ហើយយើងជាខ្មែរទាំងអស់គ្នាបានស្រែកហើយស្រែកទៀត តវ៉ាហើយតវ៉ាទៀត រហូតដល់ទទួលបានជោគជ័យ ក្នុងករណីនេះវាប្រៀបបាននឹងជាទឹកត្នោតស្រក់មួយតក់ៗ យូរៗទៅវាក៏ពេញបំពង់ដែរ ។

## ពិធីបុណ្យផ្កានៅកម្ពុជាក្រោម

ផ្កាត្រៀងជាផ្កាមួយងាយស្រួលក្នុងការធ្វើតាមទោះបីនៅទីក្រុង ឬស្រុកស្រែ ហើយក៏ជាផ្កាដែលពុទ្ធបរិស័ទមានជំនឿជឿជាក់ទៅលើព្រះពុទ្ធសាសនាទាំងនៅព្រះរាជាណាចក្រកម្ពុជា ទាំងនៅកម្ពុជាក្រោម គឺមានប្រពៃណីទំនៀមទំលាប់ វប្បធម៌ ជាពិសេសការធ្វើបុណ្យផ្កាដូចគ្នា ប៉ុន្តែពិធីបុណ្យផ្កានៅកម្ពុជាក្រោម វាមានលក្ខណៈពិសេសបន្តិចជាងបុណ្យផ្កានៅក្នុងព្រះរាជាណាចក្រកម្ពុជាយើងសព្វថ្ងៃនេះ ការដែលប្លែកនោះគឺមានខ្លឹមសារ និងអត្ថន័យដូចតទៅ ភាគច្រើនបុណ្យផ្កាជាបុណ្យមួយដែលមានការសាមគ្គីគ្នា មានអ្នកផ្តើមបុណ្យចំនួនច្រើន ហើយមានការចែកភារកិច្ចទទួលខុសត្រូវម្នាក់ៗក្នុងការទទួលភ្ញៀវបម្រើម្ហូបអាហារពេលក្នុងពិធីបុណ្យ ដោយឡែកបច្ច័យសំរាប់យកទៅកសាងវត្តអារាមគឺអ្នកផ្តើមបុណ្យទាំងអស់ជាអ្នកទទួលខុសត្រូវ ហើយចំពោះពុទ្ធបរិស័ទជាភ្ញៀវកិត្តិយសពួកគាត់តែងតែយកបច្ច័យទៅចូលតែងធ្វើជាដើមផ្កា ក្នុងមួយគ្រួសារមួយដើម ហើយគ្រប់គ្រួសារទាំងអស់ទាំងចាស់ ទាំងក្មេងនៅភូមិនីមួយៗក្នុងចំណុះជើងវត្តមានការសាមគ្គីគ្នាយ៉ាងខ្លាំងក្លាជាទីបំផុតដោយមានក្បួនដង្ហែរអង្គផ្កាពីកន្លែងគេហដ្ឋានបុណ្យឆ្ពោះទៅវត្តអារាម ដោយរមងជំណើរមានភ្លេងពិណពាទ្យនិងឆៃយ៉ាំ ព្រមទាំងគ្រូអាចារ្យមហា ទាំងព្រះសង្ឃ ទាំងគ្រហស្ថ ស្រែកជ័យឃោសនិងរាំលំលិកពងតាមផ្លូវ មានសភាពរីករាយសប្បាយរីករាយគួរជាទីគយគន់ ដូចមានរូបភាពដែលបានបង្ហាញជូនស្រាប់ ប៉ុន្តែគួរឱ្យសោកស្តាយមហាសោកស្តាយយ៉ាងក្រៃលែងនូវអ្វីដែលព្រឹត្តិបត្រអង្គការស្ត្រីខ្មែរកម្ពុជាក្រោមលើកមកបង្ហាញជូននេះ វាជារឿងដ៏ពិតគួរឱ្យកត់សម្គាល់ពីអតីតកាល ដោយឡែកបច្ចុប្បន្នកាលនេះ ប្រពៃណីទំនៀមទំលាប់ វប្បធម៌អក្សរសាស្ត្រ និងភាសាខ្មែរ ត្រូវបានយួនបំបិទសិទ្ធិសេរីភាព បំផ្លាញតាម

បន្តិចៗម្តងៗរហូតដល់សព្វថ្ងៃនេះអស់ទៅហើយ ក្រោមរបបកាន់កាប់ដ៏ឃោរឃៅ ប៉ះពាល់ទាំង និងច្បាប់ទំនៀមវិជ្ជា ប្រពៃណី ទំនៀមទំលាប់ វប្បធម៌របស់ខ្មែរ ត្រូវគេប្រែក្លាយយកតាមវៀតណាម និងពុទ្ធសាសនារបស់ខ្មែរក៏មួយថ្ងៃទៅមួយថ្ងៃបន្តិចៗម្តងៗ ជាពិសេសទៅទៀតនោះលោកគ្រូកំនិយាយអំពីជាតិកម្ពុជាក្រោម ឬខ្មែរកម្ពុជាក្រោម ឬខ្មែរក្រោម ឬសមាគមខ្មែរកម្ពុជាក្រោមនៅកម្ពុជាក្តី នៅសហរដ្ឋអាមេរិកក្តី នៅបារាំងក៏ដោយ ។ល។ សុទ្ធតែជាមុខសញ្ញាដែលគេបង្កាប់ទាំងអស់ ផង និងលោកដល់ការបោះពុម្ពកាសែតផ្សេងៗ និងរាយការណ៍ទៅជាតិអន្តរជាតិ ពាក្យនេះមានតែខ្មែរមួយ ពុក ម្រុមកំរត់ទោលស្រុកតែប៉ុណ្ណោះឯង។



ស្រណោះវត្តអារាមខ្មែរចំនួន៥៦៧វត្ត នៅដែនដីកម្ពុជាក្រោម ដែលត្រូវបានបាត់បង់ ពីការគ្រប់គ្រង និងអាណាព្យាបាលរបស់ខ្មែរ។ ទោះក្នុងកាលៈទេសៈណាក៏ដោយ ខ្មែរកម្ពុជាក្រោមនៅតែការពារថែរក្សា ប្រពៃណី ទំនៀមទំលាប់របស់ខ្លួនយ៉ាងប្តូរផ្តាច់ជាទីបំផុត។



ទិដ្ឋភាពដង្ហែបុណ្យផ្កាចេញពីគេហដ្ឋានឆ្ពោះទៅកាន់វត្តអារាម



# ខួបគម្រប់០២ឆ្នាំថ្ងៃបាតុកម្មអហិង្សារបស់សមណៈនិស្សិតនៅមុខ សាលាខេត្ត ខេត្តឃ្លាំង កម្ពុជាក្រោម ០៨ កុម្ភៈ ២០០៧-០៨ កុម្ភៈ ២០០៩

នៅថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០០៩ ក្នុងគេហដ្ឋានរបស់លោក ថាច់ សារ៉ះ មានជួបជុំគ្នាមួយនៃអង្គការសមាគមខ្មែរកម្ពុជាក្រោមមួយចំនួន ដោយមានព្រះសង្ឃចូលរួមផងដែរ បានរៀបចំរំលឹកខួប០២ឆ្នាំនៃថ្ងៃបាតុកម្មអហិង្សារបស់សមណៈនិស្សិតនៅមុខសាលាខេត្ត ខេត្តឃ្លាំង កម្ពុជាក្រោម ខណៈដែលនោះនៅបណ្តាប្រទេសមួយចំនួននៅលើពិភពលោកដូចជា សហរដ្ឋអាមេរិក កាណាដា អូស្ត្រាលី និងប្រទេសបារាំងក៏បានរៀបចំពិធីរំលឹកខួបនៃការតស៊ូអហិង្សារបស់សមណៈនិស្សិតខ្មែរកម្ពុជាក្រោមផងដែរ។ ខ្លឹមសារនិងអត្ថន័យនៃការប្រារព្ធខួបនោះគឺក្នុងគោលបំណងបង្ហាញនូវការឈឺចាប់គ្រប់ពេលវេលារបស់ខ្មែរ ដែលរស់នៅក្រោមអាណានិគមរបស់យួនសព្វថ្ងៃគឺគេធ្វើបាបគ្រប់បែបយ៉ាង ពុំឲ្យខ្មែរមានសេរីភាពអ្វីទាំងអស់ គឺរស់ដូចទឹងមោង ឬតុក្កតាតែប៉ុណ្ណោះ ទៀតហើយការឈឺចាប់របស់ព្រះសង្ឃ និងប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោមអត់ទ្រាំពុំបានរហូតឈានដល់មានការចេញមុខតទល់ជាមួយយួនដោយផ្ទាល់ វិធានការបង្ក្រាបរបស់យួនគេមានគ្រប់កំលាំងប្រដាប់អាវុធ គេមានល្បិចគ្រប់បែបយ៉ាងគេធ្វើអ្វីៗតាមតែអំពើចិត្តប៉ុណ្ណោះ។ នៅចំពោះមុខព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រនោះសមណៈនិស្សិតរបស់ខ្មែរយើងពុំមែនមិនដឹងថា វាមិនមានសេរីភាពទេ គឺយើងដឹងច្បាស់ណាស់ថាមិនត្រឹមតែមានសេរីភាពទេ គឺវាឈានដល់ទៅមានការបង្ក្រាបទៀត ប៉ុន្តែបើគេធ្វើបាបយើងហួសហេតុពេក យើងមិននិយាយ យើងមិនធ្វើក៏មិនបានដែរ ដូច្នេះវីរភាពដ៏អង់អាចក្លាហានរបស់សមណៈនិស្សិតខ្មែរកម្ពុជាក្រោមនៅលើទឹកដីដូនតារបស់យើងឯកម្ពុជាក្រោមនោះ គឺជាវីរភាពមួយដែលមិនអាចបំភ្លេចបាន។



ទិដ្ឋភាពក្នុងពិធី ជួបជុំអង្គការ សមាគមខ្មែរ កម្ពុជាក្រោម

រាល់ការជួយឧបត្ថម្ភរបស់លោកអ្នកជួយព្រឹត្តិបត្រ [illegible] សូមអរគុណ